# ការសំភាសរបស់អ្នកម៉ាក់ទៀង គឹមហុង

ក. អ្នកសំភាសឈ្មោះ គួច សុម៉ាលី ខ. អ្នកត្រូវបានគេសំភាសឈ្មោះ ទៀង គឹមហុង

**ពត៌មានសង្ខេបរបស់អ្នកម៉ាក់ ទៀង គឹមហុង**

អ្នកម៉ាក់មានទីលំនៅបច្ចុប្បន្ននៅភូមិ ស្វាយទាប ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ គាត់មានបងប្អូនសមាជិកគ្រួសារដប់ពីរនាក់។ ប្រុសដប់នាក់និងស្រីពីរនាក់(បងប្អូនស្លាប់ប្រាំបីនាក់)ហើយគាត់ជាកូនទីប្រាំមួយ ។គាត់មានស្រុកកំណើតនៅភូមិស្វាយទាប ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម
។ គាត់រៀបការនៅឆ្នាំ១៩៥៤។ អ្នកម៉ាក់មានកូនចំនួន៧នាក់ប្រុស៤នាក់និងស្រី៣នាក់។

ក៖ ឥឡូវខ្ញុំជំរាបសួរម៉ាក់ ! ថាខ្ញុំអឺ..មកពីខាងសកលវិទ្យាល័យប៊ីវាយយូ ហើយខ្ញុំមកចង់សុំការសំភាសប្រវត្តិផ្ទាល់ខ្លួនជាមួយម៉ាក់ ខ្លះៗនៅថ្ងៃនឹង ហើយអឺ..ឥឡូវជាដំបូងចង់ប្រាប់ម៉ាក់ថាខ្ញុំឈ្មោះ គួច សុម៉ាលី។តើម៉ាក់ឈ្មោះអ្វីដែរ?

ខ៖ ម៉ាក់ឈ្មោះ ទៀង គឹមហុង។

ក៖ ចាំ ! ម៉ាក់ឈ្មោះ ទៀង គឹមហុង?

ខ៖ អឹម..។

ក៖ ម៉ាក់មានអឺ..ឈ្មោះក្រៅហៅទៀតទេម៉ាក់?

ខ៖ ឈ្មោះក្រៅក៏ឈ្មោះ គឹមហុងដែរ។ អត់មានឈ្មោះអ្វីក្រៅពីឈ្មោះនឹងទេ។
ក៖ ចាំ! តើម៉ាក់អឺ..រស់នៅភូមិឃុំណាដែរបច្ចុប្បន្ននេះ?

ខ៖ រស់នៅភូមិវាលវីកើត ស្រុកចំការលើ ខេត្តកំពង់ចាម?

ក៖ ចា! ហើយតើឆ្នាំនេះម៉ាក់អាយុប៉ុន្មានដែរ?

ខ៖ ឆ្នាំនឹងអាយុ៦៥ឆ្នាំ។

ក៖ តើម៉ាក់កើតនៅថ្ងៃខែឆ្នាំណាដែរម៉ាក់?

ខ៖ នៅឆ្នាំ១៩៥៤។

ក៖ ហើយបើនៅក្នុងច័ន្ទគតិ តើម៉ាក់កើតឆ្នាំអ្វីដែរ?

ខ៖ កើតឆ្នាំមមែរខែ..ប្រាប់ខែដែរហ៎។

ក៖ ចាំ! ខែដែរម៉ាក់?

ខ៖ កើតឆ្នាំមមែរខែ..ខែអស្សុច ថ្ងៃសុក្រ។

ក៖ ឆ្នាំមមែរ?

ខ៖ ខែអស្សុច។

ក៖ ខែអស្សុច ថ្ងៃសុក្រ?

ខ៖ ថ្ងៃសុក្រ។

ក៖ អញ្ចឹង?

ខ៖ ឆ្នាំ១៩៥៤។

ក៖ ចាំ!?

ខ៖ ត្រូវនឹងអាយុ៦៤ឆ្នាំ។

កៈ ចាម៉ាក់! អញ្ចឹងទីកន្លែងកំណើតម៉ាក់នៅឯណាដែរម៉ាក់?
ខៈ ទីកន្លែងរាល់ថ្ងៃនឹងហ៎។

កៈ ចាំ!?

ខៈ នៅភូមិវារីកើត ស្រុកចំការលើ ខេត្តកំពង់ចាម។

កៈ ចាម៉ាក់! ម៉ាក់មានបងប្អូនចំនួនប៉ុន្មានដែរម៉ាក់?

ខៈ មានបងប្អូនចំនួន១២នាក់។

កៈ ១២នាក់?

ខៈ នឹងហើយ។

កៈ អញ្ចឹងតើម៉ាក់អាចរៀបរាប់អឺ...ឈ្មោះពួកគាត់ទាំងអស់គ្នាទេ?ពីកូនបងមកណា?

ខៈ កូនបងមកគាត់ឈ្មោះ..មានឈ្មោះហិប..ហ៊ាន..ហឿន..។

កះ អឺ...ម៉ាក់សុំឈ្មោះពេញបានទេ?
ខះ ឈ្មោះពេញទាំងត្រកូលហ៎។

កះ ចា! អ្នកទីមួយណា?

ខះ ទៀង ហិប..ទៀង ហ៊ន..ទៀង ហឿន..ទៀង ឈាង ហៅទូច..ទៀង ហ៊ុន..ទៀង ហ៊ាង..ទៀងហុង ទៀង គឹមហុង..ទៀង ហុន..ទៀង សាងាំ..ទៀង សម្បត្តិ។

កះ ចា! ហើយម៉ាក់ពីរនាក់ទៀតម៉ាក់?

ខះ ពីរនាក់ទៀតរកនឹកអត់ឃើញព្រោះកើតមិនទាន់ទេ។

កះ ចា!?

ខះ ហីសៗៗៗ(សើច)។

កះ អញ្ចឹងម៉ាក់ សរុបទៅម៉ាក់កូនទីប៉ុន្មានដែរម៉ាក់?

ខះ កូនទី៦។

កះ កូនទី៦?

ខ៖ នឹងហើយ។

ក៖ ហើយអឺ..កូនទាំងអស់គាត់នៅរស់ទាំងអស់រឺក៏គាត់..?

ខ៖ កូនទាំងអស់ស្លាប់៨នៅតែ៩ទេរាល់ថ្ងៃនេះ។

ក៖ ស្លាប់៨នាក់នៅ៩នាក់?

ខ៖ នឹងហើយ។

ក៖ អញ្ចឹង?

ខ៖ ប៉ុល ពត យកទៅវាយសំលាប់ចោលមួយ ក្រៅពីនឹងស្លាប់ដោយសារជំងឺរោគា ខ្លួនឯង។

ក៖ ចា! ហើយបងដែលគាត់ស្លាប់ជំនាន់ប៉ុល ពតនឹង តើគាត់អឺ...មានមុខរបរអ្វីដែរបាន...?

ខ៖ គាត់ជាទាហាន ចប់ថ្នាក់ហើយ គាត់បានធ្វើការនៅអឺ..យាន្ត..កប៉ាល់ហោះ។

ក៖ គាត់ធ្វើអ្វីម៉ាក់?នៅព្រលានយន្តហោះ?

ខ៖ ហ៊ឺយ....ម៉ែមិនសូវដឹងច្បាស់ទេកូន ប៉ុន្តែគ្រាន់តែដឹងថាគាត់ធ្វើនៅយាន្តកប៉ាល់ហោះនឹង គាត់លក់ខាងសំបុត្រកប៉ាល់ហោះ។

ក៖ លក់សំបុត្រកប៉ាល់ហោះ?

ខ៖ នឹងហើយ។

ក៖ តើម៉ាក់បានចងចាំសាច់រឿងអ្វីខ្លះពីបងប្អូនម៉ាក់ខ្លះ? ម៉ាក់អាចរៀបរាប់បានទេម៉ាក់?

ខ៖ ចងចាំអីខ្លះហ៎ា...នេតហ៎ា...ចងចាំអារឿងបងប្អូន។

ក៖ អនុស្សាវរីយ៍ពួកគាត់អីទៅណា?

ខ៖ អឺ...ចេះស្រលាញ់គ្នា នឹង
 លេងជាមួយគ្នាទៅ មើលកុនមើលល្ខោនអីទាំងអស់តែគ្នានឹងហ៎ាស..ហាស់ហាស់ៗៗ(សើច)
។

ក៖ ចា!ហាស់ហាស់(សើច)?

ខ៖ ល្ងាចឡើងនាំគ្នាទៅមើលល្ខោន ព្រោះល្ខោនវាលេងនៅមុខផ្ទះនឹងស្រាប់ណា..រឿងកុនអី ហ៎ាណា..។

កៈ ចា! ?

ខៈ ហើយអាអ្នកម្ចាស់កុននឹងក៏យកអាក្រដាស់នឹង មកអោយយើងទៅ អាសំបុត្រគេចំណាំលក់នឹងហ៉ាស..យកមកអោយ ល្ងាចឡើង គេផ្សាយគេខ្ចីរ៉ឺម៉ក អោយគេផ្សាយទៅណាដំអញ្ចឹងដល់មកវិញ គេហុចអោយម្នាក់មួយសន្លឹក ៗ ល្ងាចឡើងនាំបងប្អូនចូលទៅមើលកុនទៅ ហាស់ៗៗៗៗ(សើច) សប្បាយដែរល្ងាចៗឡើង និយាយអោយឃើញទៅសប្បាយណាស់។

កៈ ចា!?

ខៈ ល្ងាចឡើងជុំគ្នានៅមុខផ្ទះនឹងល្ងាចឡើង។

កៈ ចា!?

ខៈ អឺ..។

កៈ ហើយ នៅពេលដែលនៅក្មេងនឹង តើម៉ាក់ចូលចិត្តធ្វើអ្វីខ្លះជាមួយពួកគាត់?

ខៈ មានតែនៅ នៅក្មេងមានតែ អីនែក..លេងបៃឡុកបៃឡ ព្រលឹមឡើងទៅរៀន ថ្ងៃទៅរៀន។

កៈ ចា!?

ខៈ អត់មានពេលនៅលេងទេ មានតែទៅរៀនទេ កាលនៅពីក្មេងនោះ។

ក៖ ចា ម៉ាក់!?

ខ៖ នឹងហើយ។

ក៖ អញ្ចឹងអឺ..ពេលក្នុងពេលឥឡូវនឹងតើពួកគាត់រស់នៅកន្លែងណាខ្លះ?ហើយតើពួកគាត់កំពុងធ្វើអ្វីខ្លះដែរ?ម៉ាក់អ្នកដែលគាត់នៅរស់ណា?

ខ៖ អ្នកនៅរស់គាត់នៅ គាត់ចាស់អស់ហើយណា។

ក៖ ចា!?

ខ៖ គាត់ចាស់ៗអស់ហើយ។គាត់មានតែសម៉ាទានសិល៍ធ្វើបុណ្យធ្វើទាននឹងនៅនឹងផ្ទះនឹង។

ក៖ ចា!?

ខ៖ ប៉ុន្តែបើជំនាន់គាត់នៅក្មេង អាជំនាន់ក្មេង
គាត់រកស៊ីធ្វើពាងទៅ គាត់លក់ដូរធម្មតាទៅ ទាំងពីរនាក់នឹងបងប្អូនដែលនៅរស់សព្វថ្ងៃពីរនាក់នឹងហ៎ណា។

ក៖ ចា!?

ខ៖ ហើយពីរនាក់ទៀងរកស៊ីធម្មតាៗនឹងទេ អត់មានធ្វើការអីក្រៅពីរកស៊ីកំប៉ិកកំប៉ុកនឹងទេ។

ក៖ ហើយអឺ...ពួកគាត់រស់នៅឯណាដែរម៉ាក់?

ខ៖ មើល..ពួកគាត់រស់នៅ រស់នៅភូមិថ្នល់បែកកើត ឃុំអីនែក..ស្វាយទាបអឺ...ឃុំចំការលើ ស្រុក..ខេត្តកំពង់ចាម។

ក៖ នៅក្នុងកំពង់ចាមនឹងដូចគ្នា?

ខ៖ នៅខេត្តកំពង់ចាមនឹងដូចគ្នា គ្រាន់តែខុសភូមិ ឃុំទេណា។

ក៖ ចា!អញ្ចឹង?

ខ៖ ភូមិស្វាយ..អីនែក..ភូមិថ្នល់បែកកើតហើយម៉ាក់នៅអីវារីកើត(ភូមិវារីកើត)នឹងទៅ ខុសគ្នាតែប៉ុន...ភូមិទេ,ឃុំជាមួយគ្នាទាំងអស់ទេ។

ក៖ អញ្ចឹងម៉ាក់ហើយនឹងបងប្អូនម៉ាក់នៅទៅមក..?

ខ៖ ទៅមក។

ក៖ ជួបគ្នា..?

ខ៖ ជួបគ្នារាល់ថ្ងៃនឹង ទៅមកជួបគ្នារាល់ថ្ងៃ រាប់អានគ្នារាល់ថ្ងៃនឹង ទៅមកៗនឹងទៅណា..។

ក៖ ចាម៉ាក់!?

ខ៖ មក គាត់ចូលលេងទៅ យើងទៅនឹងទៅ ក៏បានចូលលេងគាត់ទៅ។

ក៖ ចា!  ចុះអឺ...ម្ដាយរបស់ម៉ាក់គាត់ឈ្មោះអ្វីដែរម៉ាក់?

ខ៖ ម្ដាយម៉ាក់នឹងហ៎ស។

ក៖ ចា! ម្ដាយរបស់ម៉ាក់ឈ្មោះអ្វីម៉ាក់?

ខ៖ ឈ្មោះយាយហិន តាគាត់ឈ្មោះតាសួង តែគាត់ស្លាប់បាត់ទៅហើយ។

ក៖ គាត់ស្លាប់ទាំងពីរនាក់ហ៎ម៉ាក់?

ខ៖ ស្លាប់បាត់ទាំងពីរនាក់អស់ហើយ។

ក៖ អញ្ចឹងអឺ...ម្ដាយរបស់ម៉ាក់គាត់អាយុប៉ុន្មានហើយម៉ាក់?

ខ៖ គាត់អាយុកាលគាត់ស្លាប់នឹងគាត់អាយុ៨០សិបតែគាត់ស្លាប់បាន៣ឆ្នាំមុន ៣ឆ្នាំមុន អ.. ក្រោយមកបានតាស្លាប់តាមក្រោយទៀត។

ក៖ អញ្ចឹងមានន័យថាយាយស្លាប់បាន៣ឆ្នាំបានតាស្លាប់?

ខ៖ នឹងហើយ យាយស្លាប់បាន៣ឆ្នាំបានតាស្លាប់ទៅតាមក្រោយទៀត តាស្លាប់ថ្ងៃស្លាប់នឹងគាត់អាយុ៨៥ឆ្នាំ។

ក៖ ចា!?

ខ៖ តែគាត់ស្លាប់តាំងពីស្លាប់ទៅនឹងមកដល់ឥឡូវនឹងគាត់បានដប់ឆ្នាំហើយ។

ក៖ អ៎..ចាម៉ាក់!?អញ្ចឹងបើគិតអាយុគាត់មកដល់ឥឡូវនឹង?

ខ៖ ១០ឆ្នាំហើយ។

ក៖ បើតា៩៥ ឆ្នាំហើយន៎ម៉ាក់ណោះ?

ខ៖ នឹងហើយ។

ក៖ ចា! អញ្ចឹងម៉ាក់ដឹងថ្ងៃខែឆ្នាំកំណើតគាត់កើតនៅថ្ងៃខែឆ្នាំណាដែរ?

ខ៖ ម៉ាក់មិនដឹងទេប៉ុន្តែម៉ាក់ដឹងគាត់ឆ្នាំជូតនិងឆ្នាំកុរ។

ក៖ ឆ្នាំជូតនិងឆ្នាំកុរ?

ខ៖ នឹងហើយ។

ក៖ ហើយពួកគាត់កើតឆ្នាំជូតសត្វកណ្តុរហ៎ម៉ាក់?

ខ៖ ជូតកណ្តុរ កុរជ្រូក។

ក៖ កុរជ្រូក?

ខ៖ តាកុរ យាយជ្រូក។

ក៖ យាយជ្រូក?

ខ៖ ហាស់ៗៗ(សើច)។

ក៖ តែ?

ខ៖ ហ៊ឹម...?។

ក៖ តាជ្រូក ? យាយកណ្ដុរហើយ...?

ខ៖ តាបងយាយ១ឆ្នាំ។

ក៖ ចាំ!?

ខ៖ ច កុរ ជូត..អញ្ចឹងតាកុរហើយ នែស? យាយជូត។

ក៖ តាកុរ តាជ្រូក?

ខ៖ នឹងហើយ។

ក៖ យាយកណ្ដុរ?

ខ៖ ត្រូវហើយ។

ក៖ អឺ...ពួកគាត់កើតនៅឯណាដែរម៉ាក់?

ខ៖ កើតនៅភូមិវារីចាស់ វារីចាស់នឹងហៅវារីលិច តែម្ដងទៅព្រោះនៅឯខាងស្រែកាលនឹងនៅ

ជាព្រៃគេមិនទាន់ឆ្ការទេណា។

ក៖ អញ្ចឹង?

ខ៖ នៅព្រៃខ្លាព្រៃដំរីនៅឡើយទេ គាត់នៅនឹងទេ គាត់កើតនៅនឹងទេ។

ក៖ ចា!?

ខ៖ តាមម៉ែមិនទាន់ដឹងទេណា។

ក៖ ចា!?

ខ៖ គាត់និយាយប្រាប់ ស្រុកគាត់កើតជានៅឯស្រុកវារីចាស់នឹង ភូមិវារីចាស់នឹងហៅភូមិលិចនឹងហ៉ាស់។

ក៖ អញ្ចឹងបច្ចុប្បន្នម៉ាក់នៅវារីកើត?

ខ៖ បើគេ..បើគេត្រួសត្រាយព្រៃនៅអីណោះ បាននឹងកន្លែងយើងរស់នៅរាល់ថ្ងៃនឹងក៏កន្លែងព្រៃ ព្រៃខ្លាព្រៃដំរីដែរ ប៉ុន្តែគាត់ត្រាយត្រួសនឹងទៅបានមកកើតនៅនឹងភូមិវារីចាស់ អ់..វារីកើតនៀក(នេះ)។

ក៖ ចា!?

ខ៖ នឹងហើយ។

ក៖ អញ្ចឹងមានន័យថាភូមិនឹងនៅជិតគ្នាជាប់គ្នាម៉ាក់ហ៎ស?

ខ៖ ភូមិតែមួយ ទៅអីចំការក្រោយនឹងភូមិវារីចាស់ហើយអានឹង។

ក៖ ចាម៉ាក់?

ខ៖ ភូមិចាស់ គេហៅភូមិចាស់។

ក៖ នៅជិតគ្នាអញ្ចឹងហ៎ម៉ាក់?

ខ៖ នឹងហើយ នៅជិតគ្នាទេ..ទៅមួយគីឡូពីរគីឡូដីនឹង។

ក៖ ចា?

ខ៖ ដល់ ដល់ភូមិចាស់នឹងហើយ។

ក៖ អញ្ចឹងឪពុករបស់ម៉ាក់ គាត់រកស៊ីអ្វីដែរជំនាន់នឹង?

ខ៖ រកស៊ីជំនួញ គាត់ប៉ាវចេកធ្វើចំការ ហើយប៉ាវចេក ប៉ាវបុស្សចេកគេហ៎ណា។

ក៖ ចាម៉ាក់?

ខ៖ គាត់អ្នកចំការហើយធ្វើស្រែទៀត។

ក៖ ចា?

ខ៖ ហើយទៅ.. គាត់ប៉ាវបុស្ស រួចពីគាត់ធ្វើចំការ គាត់ដើរប៉ាវបុស្សចេកគេគ្រប់កន្លែងអញ្ចឹងទៅ ...។

ក៖ គាត់រកស៊ីដែរ?

ខ៖ ដាក់ទៅខេត្តស្វាយរៀង ជិតស្រុកយួន ន់!។

ក៖ ចាម៉ាក់?

ខ៖ នឹងហើយ។

ក៖ អញ្ចឹងគាត់ជាមនុស្សបែបមិចដែរម៉ាក់តា?

ខ៖ គាត់ល្អណាស់ គេថា បើថាចាស់ទុំនៅនឹងគេគោរពគាត់ណាស់។

ក៖ចា?

ខ៖ គាត់មនុស្សល្អ មនុស្សត្រឹមត្រូវណាស់។

ក៖ចា?

ខ៖ ហើយពីណាក៏គោរពគាត់ដែរ។

ក៖ ចុះ...?

ខ៖ ចាស់មួយ ចាស់ស្រុក តែក៏គាត់ស្លាប់ទៅ។

ក៖ ចា! ចុះតើម្ដាយរបស់ម៉ាក់គាត់រកស៊ីធ្វើអ្វីដែរ?

ខ៖ យាយតាហៅស(យាយរបស់តា)។

ក៖ ចា!?

ខ៖ យាយតា(យាយរបស់តា)គាត់ធ្វើស្រែចំការដែរជំនាន់នឹង អត់មានអ្នកណាធ្វើរាជការអីទេ។

ក៖ ចា ហើយគាត់ជាមនុស្សបែបមិចដែរម៉ាក់?យាយ?

ខ៖ គឺគាត់សុទ្ធតែជាមនុស្សល្អទេ គាត់នៅនឹង។

ក៖ ចា?

ខ៖ ឮតែពេលដឹងក្តីឡើង ឮតែគេសរសើរ ដូចថាពូជយាយវិច ពូជតាសួងសុទ្ធតែពូជល្អៗដែរ នឹងហ៎ាស។

ក៖ ចាំ ចុះតើម៉ាក់ចាំសាច់រឿងអ្វីខ្លះពីឪពុកម្តាយរបស់ម៉ាក់អត់?

ខ៖ ចាំ! ចាំបានដូចថាគាត់រកស៊ីអញ្ចឹងទៅ មកវិញមកក៏គាត់អោយយើងជួយរាប់លុយរាប់កាក់នឹងហ៎ា ទាំងកណ្តាលយប់នឹងហ៎ា។

ក៖ ចា!?

ខ៖ នឹងហើយ រួចលុយមិនមែនតិចទេណា
 ទាំងបេ, បេកាបួចមាត់(បេរីការ៉ុងរឺបាវចងមាត់)ម្តងពីរបេរាប់មួយយប់ចាំទល់ភ្លឺអីបានរាប់ចប់អារឿងរកស៊ីរបស់គាត់ហ៎ា។

ក៖ អ៎ ចាំ?

ខ៖ រួចអឺ... តាំងពីដឹកចេកពីនឹងទៅ ស្វាយរៀងចូលទៅយួន
អីហ៎ ទំរាំមកវិញកណ្តាលយប់ អឺ..កណ្តាលអធ្រាតអីហ៎ ដឹក អឺ..ដូចថាគាត់បានអញ្ចឹងមកទៅ
គាត់ចង់អោយយើងមានលុយមានកាក់ខ្លួនឯងគ្រាន់ចាយគ្រាន់អីនឹងណា។

ក៖ ចាម៉ាក់?

ខ៖ ព្រោះយើងមិនចេះយក គាត់អោយប៉ុន្មានក៏យកទៅ។

ក៖ ចា៎?

ខ៖ ដឹងសាច់រឿងដែលគាត់ចង់អោយយើងសប្បាយចង់អោយយើងស្អាត ហ៊ីហាអីនឹង អោយ
លុយអោយកាក់អញ្ចឹងទៅ។

ក៖ ចា?

ខ៖ ទាន់គាត់អញ្ចឹងដែរណា ទាន់គាត់ អាដែង..រកស៊ីជំនាន់នឹងសប្បាយចិត្តណាស់គាត់មានបា
នដល់មកកូនៗធ្លាក់ខ្លួនក្រអញ្ចឹង,ធ្លាប់តែគាត់មានន៎ សប្បាយណាស់។

ក៖ ចាម៉ាក់! អញ្ចឹងម៉ាក់ធ្លាប់ដែល អ៎..គាត់មានដែលធ្លាប់ប្រាប់ម៉ាក់ពីជីវិតគាត់កាលពីក្មេងទេ?

ខ៖ ពីនៅក្មេងគាត់ធ្លាប់បួសនៅវត្តជាំក្សាន្តណា៎ស់។

ក៖ ចា?

ខ៖ វត្តជាំក្សាន្តខេត្តព្រះវិហាន៎ គាត់ធ្លាប់បួសតាំងពីតូចម្ល៉េះ។

ក៖ ចាម៉ាក់?

ខ៖ នឹងហើយ។

ក៖ គាត់បួសប៉ុន្មានឆ្នាំម៉ាក់?

ខ៖ ហ៊ឹម..មិនបានចាំដែរទេនៀក គាត់ធ្លាប់គាត់គ្រាន់តែថាគាត់បួសនៅវត្តជាំក្សាន្តតាំងពីអាយុជាង១០ឆ្នាំបន្តិចបន្តួចនឹង រហូតដល់គាត់ដូចថាវ័យចាស់ចំណាស់ល្មមដណ្តឹងប្រពន្ធបានហើយគាត់សឹកមកដណ្តឹងយាយយក។

ក៖ ចា?

ខ៖ នឹងហើយ។

ក៖ អញ្ចឹងប្រហែលជាគាត់រៀននៅវត្តហើយន៎ម៉ាក់?

ខ៖ គាត់រៀននៅនឹងសាលាវត្តទេ។

កៈ ចា?

ខៈ គាត់អត់មានរៀននៅនឹងសាលាយើងទេ គាត់រៀនចេះ ចេះច្រើនហ្មង់នៅវត្តនឹង។

កៈ អញ្ចឹងនិយាយពីជីដូនជីតារបស់ម៉ាក់វិញតើម៉ាក់ចងចាំឈ្មោះជីដូនជីតាម៉ាក់អត់ ជីដូនឈ្មោះអី ជីតាឈ្មោះអី?

ខៈ ជីដូនឈ្មោះយាយវិច , ជីតាឈ្មោះតាអ៊ុំ ,តាទៀង ហើយទៅយាយអ៊ឹម ..ស្គាល់ប៉ុន្នឹងទេចៅ..កូន..។

កៈ ចុះអ៊ឺ..?

ខៈ ភ្លេចអស់ហើយ។

កៈ ជីដូនខាងប៉ាគាត់អ៊ឺ..ឈ្មោះ?

ខៈ ខាងប៉ាហ៉ែង..ទាល់តែគេបានគេស្គាល់។

កៈ ខាងតា?

ខ៖ តាណា? តាសួងហ៊ស។

ក៖ ចា?

ខ៖ ខាងតាសួងយាយរិចនឹង។

ក៖ យាយរិចម្នាក់?

ខ៖ អឺ..ស្គាល់តែយាយរិចម្នាក់ទេ។

ក៖ ចុះខាងយាយ?

ខ៖ ខាងយាយឈ្មោះយាយហ៊ីង។

ក៖ យាយហ៊ីង?

ខ៖ យាយអ៊ឹម ។

ក៖ យាយអ៊ឹម ?

ខ៖ អ៊ំ..យាយអីទៀតទេ ភ្លេចអស់ហើយអត់ស្គាល់ទេ..ស្គាល់បានប៉ុន្នឹងទេ។

កៈ ចុះម៉ាក់ចាំថ្ងៃខែឆ្នាំកំណើតគាត់ទេ?

ខៈ មិនចាំទេកូន មិនចាំទេ មិនដឹងគាត់ឆ្នាំអី អាយុប៉ុន្មានផងនឹង។

កៈ ឆ្នាំអីក៏អត់ចាំដែរម៉ាក់?

ខៈ អត់ចាំសោះ។

កៈ ចុះម៉ាក់ធ្លាប់ដឹងពីរឿងរ៉ាវរបស់ពួកគាត់ខ្លះទេ?

ខៈ ធ្លាប់ដឹង ដឹងគាត់ថា..ដឹងក្ដីមកស្គាល់គាត់ ដឹងថាគាត់ធ្វើបុណ្យតែម្ដង មួយឆ្នាំគាត់ធ្វើបុណ្យម្ដងៗ ដឹងតែប៉ុន្នឹង។

កៈ ចាម៉ាក់?

ខៈ នឹងហើយ, ហើយគាត់ចាស់ៗអស់ហើយនឹងហ៎ស គាត់រកស៊ីអីកើតទេ,គាត់ដឹងតែធ្វើបុណ្យធ្វើសិល៍តែប៉ុន្នឹង។

កៈ ចា អញ្ចឹងតើក្រុមគ្រួសាម៉ាក់រស់នៅខេត្តកំពង់ចាមនឹងយូហើយរឺក៏រយៈពេលប៉ុន្មានឆ្នាំដែរ?

ខ៖ ដឹងក្ដីមក គឺរស់នៅកន្លែងភូមិវារីកើតនឹងតែម្ដង នៅខេត្តកំពង់ចាមនឹងណាស់។

ក៖ ចា?

ខ៖ ដឹងក្ដីកាលណា ស្គាល់នៅកន្លែងនឹងតែម្ដងអត់មានទៅនៅកន្លែងណា រឺកន្លែងទៅឯណាទៀតទេ នៅតែមួយកន្លែងនឹង។

ក៖ ចា អញ្ចឹងអឺ...តាមឮម៉ាក់និយាយប៉ា ..តានឹងតាទូតគាត់..?

ខ៖ ជាជន្លងនឹងគ្នាទេ តែជំនាន់នឹងជំនាន់អីសារ៉ាក់ បារាំងនឹងណា។

ក៖ ចា?

ខ៖ ចាប់រៀបការអោយយាយនឹងតានឹង គឺជន្លងនិងជន្លង។

ក៖ ចា?

ខ៖ បើយើងមិនយក គេសំលាប់ចោល ជំនាន់អីសារ៉ាក់បារាំងនឹងណា។

ក៖ ជំនាន់អីសារ៉ាក់នឹងឆ្នាំណា?

ខ៖ ឆ្នាំ៥៣-៥៤..(១៩៥៣)បើមិន៥៣-
៥៤ នឹងនែ៎ស។ ប៉ុន្តែអញកើតមកជំនាន់នឹងវា ថាអត់ទាន់..វាផុតសង្គ្រាមអស់,អញ្ជឹងបានន័យថា ម៉ែកើតមកនឹងផុតសង្គ្រាមអស់ហើយ វាមានតែ៥៣ហើយ-៥៤ហើយ។

ក៖ ចា?

ខ៖ យើងលែងមានសង្គ្រាមណា។

ក៖ ចាម៉ាក់?

ខ៖ ខ្លាំងដែរសង្គ្រាមកាលនឹងធំណាស់,គេថាធំណាស់,សង្គ្រាមម៉ាហិកនឹង(សង្គ្រាមពេលនឹង)ន៎,មានតែជំនាន់នឹងទេ ជំនាន់អីសារ៉ាក់។

ក៖ អញ្ជឹងមានន័យថាក្រុមគ្រួសាររបស់ម៉ាក់នឹងរស់នៅខេត្តកំពង់ចាមតាំពី១៨៥០ជាងរឺក៏មុន ?

ខ៖ ១៩៥៤ទេហ៎ែសនេត? មិនមែន១៨០០ទេហ៎ែស១៩៥៤ណា។

ក៖ មិនមែនជំនាន់តាទេជំនាន់តាទួតណា?

ខ៖ អឺៗ...។

ក៖ អញ្ជឹងបើអឺ...ម៉ាក់អាចដឹងមុនតាទួតទៀតទេ?ជំនាន់មុនតាទួតគាត់នៅកំពង់ចាមនឹងដែររឺក៏

យ៉ាងម៉េច?

ខ៖ មិនដឹងថាជំនាន់ណាមិនស្គាល់ទេហ៎ា។

ក៖ អស់ត្រឹមតាទួតនឹងហ្មង?

ខ៖ បើថាតាទួតបែបដឹង បើថានេះ នៅដឹងក្តីមកដឹងថាគាត់នៅកន្លែងនឹងទាំងអស់តែគ្នានឹង។

ក៖ អញ្ចឹងយូឆ្នាំហើយ យូមែនទែនណា?

ខ៖ យូហើយ។

ក៖ អញ្ចឹងម៉ាក់តើម៉ាក់មានអឺ..បងប្អូនរឺសាច់ញាតិនៅក្រៅប្រទេសរឺអត់?

ខ៖ មាន អត់មានទេមិនមានទេមានតែបងប្អូននៅក្បែរគ្នាប៉ុន្នោះ។

ក៖ ម៉ាក់មានស្វាមីៗគាត់ឈ្មោះអ្វីដែរម៉ាក់?

ខ៖ ឈ្មោះឡុង សុខខៃហៅតាច្រឹក។

ក៖ ឈ្មោះក្រៅគាត់ហៅតាច្រឹក?

ខ៖ តាច្រឹកហាសៗៗ(សើច)។

ក៖ ម៉ាក់រៀបអាពាហ៍ពិពាហ៍នៅពេលណាដែរម៉ាក់?

ខ៖ រៀបអាពាហ៍ពិពាហ៍នៅឆ្នាំ១៩៧៥។

ក៖ ឆ្នាំ៧៥(១៩៧៥)?

ខ៖ ជំនាន់ប៉ុល ពត។

ក៖ ចា, ចុះអាពាហ៍ពិពាហ៍របស់ម៉ាក់នឹង រៀបចំឡើងដោយឪពុកម្តាយរឺក៏ម៉ាក់ផ្ទាល់ខ្លួនឯង?

ខ៖ រៀបចំដោយឪពុកម្តាយតែអាពត(ប៉ុល ពត)ជាអ្នករៀបអោយ,ម៉ែឪអ្នកសំរេច,តែអាពត(ប៉ុល ពត)អ្នករៀបការអោយ។

ក៖ អញ្ចឹងមានន័យថានៅក្នុងជំនាន់ ប៉ុល ពត រៀបការនឹង?

ខ៖ នឹងហើយ នៅជំនាន់ ប៉ុល ពត ឆ្នាំ១៩៧៥ ប៉ុល ពត វាចាប់ផ្តើមហើយណា។

ក៖ ចាម៉ាក់?

ខ៖ នឹងហើយ,តែនៅបាយតាមផ្ទះនៅឡើយទេ, វាអត់ទាន់បាយឆ្នាំងធំទេ។

ក៖ ចាំ?

ខ៖ នៅបាយ,អានឹងបាយតាមផ្ទះ។

ក៖ ជំនាន់ ប៉ុល ពត ដែលម៉ាក់រៀបការនឹងគឺ...?

ខ៖ នៅមានលោកសង្ឃ,នៅលោកសង្ឃនៅសូត្រមន្ត សូត្រអីអោយណា។

ក៖ ចាំ!នៅក្នុងខេត្តកំពង់ចាមនឹងដដែលម៉ាក់ហ៎?

ខ៖ នឹងហើយ។

ក៖ ភូមិដដែលនឹងហ៎ស?

ខ៖ នៅភូមិដែលកើតដដែលនឹងភូមិវារីកើត។

ក៖ អ..ចាម៉ាក់?

ខ៖ ស្រុកចំការលើ ខេត្តកំពង់ចាមនឹង។

ក៖ ចា ! ចុះនៅពេលរៀបការនឹងមានថ្លៃជំនូនថ្លៃអី..?ខ្លះអត់ម៉ាក់?

ខ៖ មាន ! ចេកពីរអម្រែក ហាសៗៗ(សើច) ក្រណាត់ប្រឌិបខ្មៅ..ហាស់ៗៗ(សើច)ពីរ ស ..មួយកំប្លេ,អាវមួយ សំពត់មួយមានក្រម៉ាបង់កមួយ អាជំនាន់ ប៉ុល ពត ដឹងស្រាប់ហើយ មានតែសំពត់ខ្មៅនឹង វាលេខមួយហើយ វាពិសេសហើយ,តេតារ៉ុងនឹងហ៎ណ៎ា។

ក៖ ចា?

ខ៖ វាលេខមួយហើយ។

ក៖ អញ្ចឹងការសំរេចនឹងមិនមែនលើតែប៉ាម៉ាក់របស់ម៉ាក់ទេ លើអាពតទៀត?

ខ៖ ការសំរេចគឺលើម៉ែនឹងប៉ាណាស់...តាយាយណាស់។

ក៖ ចា?

ខ៖ គាត់រៀបទុកអោយ តែដល់ពេលរៀបឡើងទៅធ្វើមេទិញ(មេទិញគឺកន្លែងប្រជុំ)គឺអាពតគេអ្នកយកទៅកន្លែងមេទិញគេ។

កៈ ចាម៉ាក់?

ខៈ នឹងហើយ, ជំនាន់នឹងសុទ្ធតែអញ្ចឹង ការម្តង៩គូរ ៧គូរ ១០គូរ ហាស់ៗៗ(សើច)។

កៈ អញ្ចឹងកាលម៉ាក់ការនឹងម៉ាក់ការប៉ុន្មានគូរដែរ?

ខៈ ៩គូរ។

កៈ ៩គូរហើយ សុទ្ធតែអាពត ការអោយទាំងអស់ហ៎ម៉ាក់?

ខៈ អាពតការអោយទាំងអស់។

កៈ អ!..ហើយម៉ាក់ ហើយប៉ាបាន..បាន..បានជួបគ្នាមុនរឺក៏ស្គាល់គ្នាមុនដែររឺអត់ជំនាន់នឹង?

ខៈ ស្គាល់គ្នាមុនហើយ,ធ្លាប់ស្គាល់គ្នាមុនជំនាន់នឹង ជំនាន់ ប៉ុល ពត នឹង គេអោយប៉ាឯងធ្វើរ ប្បធម៌ គ្រូបង្រៀនណាស់។

កៈ ចាម៉ាក់?

ខៈ គេមួយថ្នាក់ ម៉ាក់មួយថ្នាក់ទៅ, ធ្វើគ្រូដូចគ្នា។

កៈ ហើយម៉ាក់បានចាប់អារម្មណ៍គ្នាដែរ?

ខៈ មិនចាប់អារម្មណ៍ទេគ្រាន់តែ គេស្រលាញយើង គេលួចស្រលាញ់ពីអង្គាល់ផង។

កៈ អញ្ចឹងមានន័យថាប៉ាជាអ្នកចាប់អារម្មណ៍ម៉ាក់មុនគេ?

ខៈ ហ៊ឹម...គេលួចស្រលាញ់យូហើយ តែម៉ាក់មិនដឹងខ្លួនថាគេស្រលាញ់ទេ គេតាមយកទាល់តែបាននឹង។

កៈ ចាំ?

ខៈ ដល់មិនបាន គេប្រាប់ប្រធានភូមិរឹសង្កាត់នឹងអោយមកដណ្តឹងយើងទៀត ហ៊ឹសៗៗ(សើច)។

កៈ ហ៊ឹសៗៗ(សើច)?

ខៈ បើយើងមិនអោយ គេអោយយើងលីអាបេទៅសមរភូមិមុខ ហ៊ឹសៗៗ(សើច)។

កៈ ចូលលក្ខណៈគំរាម..?កំហែង?

ខៈ ហាស់ ហាស់..(សើច)អ្នកណាដាច់ចិត្តអោយកូនលីអាបេទៅសមរភូមិ,បើមិនអោយ..មិនអញ្ចឹង?។

កៈ ចា?

ខៈ យើងមិនយកក៏ត្រូវតែយកដែរ ពេលនឹង។

កៈ អញ្ចឹងមានន័យថាម៉ាក់បង្ខំចិត្តដែរ?

ខៈ  ហ៊ីសៗៗ(សើច)។

កៈ អញ្ចឹងជំនាន់នឹងម៉ាក់ចេះភាសាខ្មែរច្បាស់លាស់ទេ?ម៉ាក់រៀនភាសាខ្មែរច្បាស់លាស់ទេ?

ខៈ រៀនច្បាស់តើ! រៀនភាសារខ្មែរច្បាស់ ភាសាបារាំងច្បាស់ណាស់កាលនុង(កាលនឹង)ប៉ុន្តែឥឡូវនឹងដូចថា វាភ្លេចអស់ហើយ លែងនឹកឃើញអស់ហើយណា ភ្លេចអស់ហើយណាស់។

កៈ ម៉ាក់ចេះភាសាបារាំងដែរហ៎?

ខៈ ម៉ាក់ចេះភាសាបារាំងហើយចេះបកប្រែទៀត
ចេះច្រើនកាលនឹងហ៎ ជំនាន់នឹង តែឥឡូវភ្លេចអស់ហើយ ប្រលងពេល
ដូចថា..ពេលគេចុះមក គ្រូថ្នាក់លើ គេចុះមកចង់សាកកន្លែងសិស្សយើងនឹងណា នៅថ្នាក់នឹងណាស់។

កៈ ចាំ?

ខ៖ គេសួរ ម៉ាក់បានលេខមួយណា។

ក៖ ចាំ?

ខ៖ ឆ្លើយភាសាបារាំង គេ.. បារាំងណា គេចុះមកនិយាយជាមួយយើង បារាំងនឹងហ្មង់ណា! យើងឆ្លើយវិញបារាំង គេនៅ.. វីវី! វីវី! វាល្អរវាហ៎ណា។

ក៖ ចាំ! អឺម...អញ្ចឹងម៉ាក់ពូកែណាស់។

ខ៖ វាដូចថា វាសសើយើង ៗ យើងឆ្លើយទៅត្រូវហ៎ វាអរ កាខិបកាខុប វាឆ្លើយមក យើងឆ្លើយទៅវិញត្រូវហ៎។

ក៖ អញ្ចឹងកាលជំនាន់នឹងម៉ាក់រៀនថ្នាក់..ចប់ត្រឹមថ្នាក់ទីប៉ុន្មានដែរម៉ាក់?

ខ៖ ថ្នាក់ទី៧ កាល់ជំនាន់នឹងហ៎ រួចទៅ ស្រុកកើតសង្គ្រាមហើយ។

ក៖ ចាំ?

ខ៖ ស្រុកកើតសង្គ្រាមនឹងក៏យើងលែងបានរៀនហើយព្រោះរៀនបានត្រឹមថ្នាក់ទី៧ទេ ទី៧ចប់ទី៧ហើយណា។

ក៖ ចាសម៉ាក់?

ខ៖ នឹងហើយស្រុកកើតសង្គ្រាមហ្មង។

ក៖ ចាំ?

ខ៖ នឹងហើយ លន់ ណុល ! ជំនាន់ លន់ ណុល កាលនឹង។

ក៖ អញ្ចឹងសាលារៀនម៉ាក់នៅណាកាលនឹងម៉ាក់?

ខ៖ នៅស្វាយទាបនឹង ស្រុកចំការលើ ខេត្តកំពង់ចាម។

ក៖ សាលាឈ្មោះអីដែរម៉ាក់?

ខ៖ សាលាបឋមសិក្សាស្វាយទាប។

ក៖ សាលាបឋមសិក្សាស្វាយទាប?

ខ៖ នឹងហើយ។

កៈ ចាំ! តើម៉ាក់មានមិត្តភក្តិស្និទ្ធស្នាលដែលធំធាត់ជាមួយគ្នានឹងជិតស្និទ្ធ មានទេម៉ាក់?

ខៈ មាន! តែគេនៅឆ្ងាយៗអស់ហើយគ្មានទេ នៅស្រុកមានម្នាក់ពីរនាក់ដែលស្គាល់គ្នាស្និទ្ធស្នាលនឹងហ៎ា។

កៈ ចាស! គាត់ឈ្មោះអ្វីខ្លះទៅម៉ាក់?

ខៈ មើល!! ឈ្មោះនារី នឹងមួយ..ឆេង ហ័នពីរ គេទៅនៅឆ្ងាយៗ ប៉ុន្តែបើជួបគ្នាម្តងៗ ក៏ឃើញគ្នាក៏ចេះតែស្រលាញ់គ្នានិងគ្នាទៅណា..។

កៈ ចាសម៉ាក់?

ខៈ ស្រវ៉ាអោបគ្នា ដូចថា.. វាធ្លាប់រស់នៅ កាលនៅនឹងរៀនជាមួយគ្នា ធ្លាប់លេងជាមួយគ្នា ធ្លាប់អាដែង..ទៅណាក៏ជាមួយគ្នាដែរ បានស្អីហូបចុកក៏ជាមួយគ្នាដែរ បានស្អីហូបចុកក៏ចែកគ្នាដែរណា។ ដល់តែបែកឆ្ងាយអញ្ចឹងមកឃើញគ្នាម្តងៗ ស្រវ៉ាអោបគ្នាទៅណា។

កៈ ចាស?

ខៈ នឹងហើយ ហ៊ីសៗៗ(សើច)។

កៈ ហើយ ម៉ាក់ចាំរឿងអីខ្លះពីពួកគាត់ដែរម៉ាក់?

ខ៖ ចាំ! អឺ..ថាបានលេងមឹកលេងអីជាមួយគ្នានិង នៅសាលាមានស្អីមានតែមឹក ហ៊ីសៗៗ(សើច)។

ក៖ ចាំ ហ៊ីសៗៗ(សើច)?

ខ៖ លេងមឹក លោតអន្ទាក់ លោតអីនឹង។

ក៖ ហើយ ម៉ាក់! កាលពីពេលនឹងម៉ាក់ធ្វើអីគេខ្លះ?ធ្វើកិច្ចការងារអ្វីខ្លះបន្ទាប់ពីរៀនម៉ាក់?

ខ៖ បន្ទាប់ពីរៀនមកជួយម៉ែឪធ្វើស្រែចំការនឹង ធ្វើស្រែច្រូតស្រូវ ច្រូតអីនឹងហ៎ាស ។ បើអស់ការងាររៀននឹង មកធ្វើការងារចំការ ធ្វើស្រែគាត់នឹង។

ក៖ អ..! ម៉ាក់កាលជំនាន់នឹង មានអាជីវកម្មគ្រួសាដែររឺអត់?

ខ៖ មានអាជីវកម្មធ្វើស្រែធ្វើចំការអីនឹងអែង អត់មានរកអីទេ មានតែស្រែចំការ។

ក៖ តើក្នុងជីវិតរបស់ម៉ាក់ ម៉ាក់មានធ្វើការងារអីទៀតទេម៉ាក់? ក្រៅពីស្រែចំការ?

ខ៖ មួយជីវិតរបស់ម៉ាក់ មានតែចំការ មានតែធ្វើចំការមួយមុខនឹង អត់មានធ្វើអីទេ។

ក៖ ធ្វើដល់ឥឡូវទេម៉ាក់?

ខ៖ ឥឡូវធ្វើលែងកើតហើយ ព្រោះចាស់ៗអស់ហើយ អត់មានកំលាំងតស៊ូទៀតទេ។

ក៖ ចាសម៉ាក់?

ខ៖ នឹងហើយ។

ក៖ អញ្ចឹង..?

ខ៖ ធ្វើចំការជួលអោយគេ ចំការជួលអោយគេ អត់មានធ្វើខ្លួនឯងកើតទេ ពីព្រោះថាធ្វើវាទៅមិនរួច ទារុនទារាអស់ហើយ។

ក៖ កំលាំងអត់ដល់ន់ម៉ាក់?

ខ៖ កំលាំងមិនដល់ហើយក៏មិនមានកូនណា គេនៅជួយយើងដែរ គេសុទ្ធតែមានគ្រួសារបែករៀងៗខ្លួនអស់ហើយណា។

ក៖ ចាសម៉ាក់?

ខ៖ អញ្ចឹងនៅតែពីរនាក់យាយតាហើយអាកូនមួយនឹងមេម៉ាយនឹង ក៏វាពិបាកពឹង។

កៈ ចុះម៉ាក់មានកូនប៉ុន្មាននាក់ដែរ?

ខៈ កូនប្រាំពីរនាក់ នៅទាំងអស់នឹង។ចុះអាពៅវានៅរៀននៅឡើយណា។

កៈ ម៉ាក់អាចរៀបរាបឈ្មោះពីដើមមក..?

ខៈ ពីដើមកូនបងគេ លីណា..។

កៈ ឈ្មោះពេញម៉ាក់?

ខៈ តែម ម៉ាលីណា ហើយគ្រួសាគេឈ្មោះពេទ្យប៉ូ។

កៈ ចាំ?

ខៈ ហើយទីពីរ លីដាហើយនិងអាណោត។

កៈ តែម ម៉ាលីដា?

ខៈ នឹងហើយតែម ម៉ាលីដានិងណោត។

កៈ ចាំម៉ាក់?

ខៈ ហើយគេនៅភ្នំពេញដែរ គេធ្វើការនៅភ្នំពេញ លីណាក៏វាធ្វើការណា។

កៈ ចាំ?

ខៈ ចុះមក អាដែង ឌី មួយទៀតនឹងពោះម៉ាយ។

កៈ តែម ម៉ាលីឌី?

ខៈ ពោះម៉ាយក៏វាមិនដឹងរកអីដែរ វានៅស៊ីផឹក ស៊ីផឹក អត់គិតការងារធ្វើហំណា ពិបាកពឹងពាក់ណា ដ៏អញ្ចឹងទាល់តែនៅចិញ្ចឹមវាមានថៅមួយទៀត។

កៈ ចាំ?

ខៈ ហើយក្រោយមកយ៉ិប តែម ម៉ាលីនី
នឹងសុភាព សុភាពនឹងគេមានមុខជំនួញគេរកស៊ីលក់ដូរនឹងទៅ គេបើកឃ្លាំងជួញដូរអាដែង ស្រាបៀរស្រាអីទៅនឹងណា។

កៈ ចាម៉ាក់?

ខ៖ អឺ..ហើយទៅបានមកលីនី លីណូ លីណូមានគ្រួសារមួយថ្ងៃមុននឹងហើយណាស់ រៀបការអោយគេហ៎ាស។

ក៖ ចាម៉ាក់?

ខ៖ អឺ..រៀបការអោយគេនៅបាត់ដំបងនឹងហ៎! ទៅដោយឡែកៗអញ្ចឹងហ៎ ហើយ...។

ក៖ គាត់ធ្វើការដែរ?

ខ៖ នឹងហើយ គេធ្វើការរកស៊ីទាំងពីរនាក់ប្តីប្រពន្ធនឹង ហើយអាពៅនឹងវាជាប់រៀន។ អូ..នៅស្រីណាតមួយទៀត ភ្លេច! បានមកអា ស្រីណាត ស្រីណាតគេធ្វើការនៅកន្លែងស្រុក មន្ទីពេទ្យបង្អែកស្រុក ពីរនាក់ប្តីគេនឹង ពេទ្យទាំងពីរនាក់។

ក៖ ចាំ?

ខ៖ បានមកអាអូន អាអូន តែម តែម វីរៈ។

ក៖ ចាម៉ាក់?

ខ៖ តែម វីរៈនៅរៀននៅឡើយ បានត្រឹមថ្នាក់ទី..បានឆ្នាំទីបីហើយ។ នៅពីរឆ្នាំទៀតបានបញ្ចប់ថ្នាក់។

ក៖ ចាំ?

ខ៖ បាន បានចេញការងារ អញ្ចឹងនៅបន្ទុកតែមួយនឹងទេ ក្រៅពីនឹងគេមានគ្រួសា គេបែកខ្ញាយអស់ហើយ ហើយគេនៅ គេរករៀងខ្លួនណា គេគ្មានពេលមកជួយយើងទេ។ អញ្ចឹងនៅអាពៅមួយកំពុងតែរៀន នៅសព្វថ្ងៃបើនិយាយទៅនៅតែម៉ាក់ហើយនឹងប៉ានឹង សុទ្ធតែចាស់ៗអស់ហើ

យ។

ក៖ ចាំ អញ្ចឹងនៅក្នុងបន្ទុករាល់ថ្ងៃនេះនឹងម៉ាក់នៅសល់តែអាអូនពៅមួយហើយ?

ខ៖ តែអាពៅមួយនឹង។

ក៖ ហើយនឹង?

ខ៖ តែម វីរៈមួយទេដែលកំពុងតែបន្តវិជ្ជាវា នៅពីរឆ្នាំទៀតបានបញ្ចប់។

ក៖ ចាំ?

ខ៖ នឹងហើយ។

ក៖ តែកូនក្រៅពីរនឹងគេការហើយ គេបែកអស់ហើយ។

ខ៖ ហើយគេធ្វើការរៀងខ្លួន គេគ្មានពេលណាមកជួយយើងធ្វើចំការទេ ធ្វើអីទៀតទេណា។

ក៖ ចាំម៉ាក់?

ខ៖ អញ្ចឹងនៅម្នាក់ឯងពីរនាក់យាយតាទៅណាវាពិបាក កំលាំងក៏វាអន់។

ក៖ ចាំ?

ខ៖ មានអ្នកណាជួយអញ្ចឹងសល់តែដីចំការតិចតួច នឹង ជួលអោយគេទៅ។

ក៖ ចាំម៉ាក់?

ខ៖ ដើម្បីយកសាហ៊ុយ(លុយ)មកទប់ទល់អោយអាកូននៅរៀននឹង។

ក៖ ចាំ! តើអឺ..តាំងពីក្មេងរហូតដល់ឥឡូវនឹង តើជីវិតម៉ាក់មានការផ្លាស់ប្តូរអ្វីខ្លះម៉ាក់?

ខ៖ មាន..ពីក្មេងវាមានកាលំបាកខ្លាំងណាស់ជំនាន់ កាលចាប់ដៃគ្នាជំនាន់អាពត(ប៉ុលពត)នឹង ហ៎ា។

ក៖ ចាំ?

ខ៖ វាមានអីវាពិបាក ពិបាករហូត រហូតដល់មកឥឡូវនេះ អើ..វាបានគ្រាន់បើច្រើន មិនថាដូច ថាវាមិនពិបាកដូចជាជំនាន់ចាស់ៗ។ ក្មេងៗជំនាន់អាពត(ប៉ុលពត)ណាដេកភ័យ ខ្លាចគេយក ទៅវាយចោល(សំលាប់ចោល)ណាដេកភ័យ ថាវាស៊ីវាមិនពេញពោះណាស់ បើករបបអោយ យើងស៊ីមួយគែៗ មិនពេញពោះទេ ហើយគេហៅយើងទៅប្រើ ម៉ោងមួយម៉ោងពីរអីអញ្ចឹងទៅ ។ ងើបទៅច្រូតស្រូវ នៅអង្គុយកណ្តាលថ្ងៃ..អ កណ្តាលយប់នឹងចាំគុម្ពស្រូវទំរាំតែភ្លឺថ្ងៃរះបើក ថ្ងៃមកបើកពន្លឺមកបាន យើងមើលស្រូវឃើញបានច្រូត។ អញ្ចឹងគេដាស់យើងទៅអង្គុយនៅក ណ្តាលវាលស្រែនឹងទាំងកណ្តាលយប់នឹងណា។

ក៖ ចាំ?

ខ៖ ម៉ោងមួយម៉ោងពីរគេហៅយើងទៅហើយ តែឥឡូវនឹងគេអត់មានការពិបាកអីទេ វាស្រួល ច្រើនឆ្ងាយណាស់ វាលែងពិបាកលែងព្រួយអីហើយ។

ក៖ ឥឡូវធូជាងមុន?

ខ៖ ឥឡូវធូជាងមុន រស់ក៏គ្មានពីណា(អ្នកណា)មកបង្ខំយើងណាស់។

ក៖ ចាម៉ាក់?

ខ៖ នឹងហើយមិនមែនដូចជំនាន់ ប៉ុល ពត ទេ។

ក៖ ចុះអឺ..ម៉ាក់ចូលចិត្តហូបម្ហូបអ្វីខ្លះម៉ាក់?

ខ៖ ម្ហូបអីក៏ម៉ាក់ហូបដែរ។

ក៖ ចំណូលចិត្ត?

ខ៖ មិនរើសអីទេ ស្អីក៏ម៉ាក់ចូលចិត្តទាំងអស់។

ក៖ អញ្ចឹងកាលពីក្មេងម៉ាក់ចូលចិត្តលេងល្បែងអីជាងគេ?

ខ៖ ពីក្មេងចូលចិត្តលេងល្បែងលោតអន្ទាក់ ឈូសមឹក អើមានតែប៉ុណ្ណឹងក្មេងៗណាស់ គប់កង ណាស់ ហើសៗៗ(សើច)។

ក៖ ម៉ាក់កាលពីក្មេងម៉ាក់មាននៅចាំចំរៀងម៉ាក់នៅពីក្មេងទេ?ម៉ាក់ចូលចិត្តចំរៀងណាជាងគេ?

ខ៖ ចូលចិត្តចំរៀងពីសង្គមចាស់ ចំរៀង រស់ សេរីសុទ្ធា និង ស៊ិន ស៊ីសមុត្រ ចូលចិត្តណាស់។

ក៖ ចាំ !បទអីខ្លះដែរម៉ាក់ចូលចិត្តជាងគេ?

ខ៖ ម៉ាក់ ភ្លេចអស់ហើយកូន គ្រាន់តែម៉ាក់ចាំថាចំរៀង ស៊ិន ស៊ីសមុត្រ និង រស់ សេរីសុទ្ធា ប៉ែន

រ៉ែន អីនឹងណាស់ ហ្វូយ មាស អីនឹងពួករ៉ូង(រ៉ុល)ពីសង្គមអីនឹង គឺម៉ាក់ចូលចិត្តទាំងអស់។

កៈ ចាម៉ាក់?

ខៈ អោយតែចំរៀងពួកអ្នកពីសង្គម។

កៈ ក្នុងគ្រួសារម៉ាក់តើមានកូនចៅ រឺអ្នកណាម្នាក់ចេះភ្លេង? ចេះភ្លេងទេ?

ខៈ អត់មាន អត់មានពីណាចេះ(អ្នកណាចេះ)ភ្លេងទេ សុទ្ធតែអ្នករៀនអក្សរទាំងអស់ អត់មានអ្នកណារៀនភ្លេងផង។

កៈ ចុះផ្ទះម៉ាក់មានលក្ខណៈយ៉ាងម៉េចដែរ? តាំងពីក្មេងរហូតដល់ឥឡូវ?

ខៈ ផ្ទះម៉ាក់ ចាប់តាំងពីចាប់ដៃគ្នាមក នៅផ្ទះស្បូវកាដូប(តូច) ជញ្ជាំងស្លឹកដូង ជញ្ជាំងខ្ទមឫស្សីលិចមុខលិចក្រោយ រាងផ្ទះធ្លាយហ៉ាសៗៗ(សើច)ភ្លៀងមកអូសកន្ទេលដេករកកន្លែងដេកជ្រក ហាសៗៗ(សើច)។

កៈ ហីសៗៗ?

ខៈ ហើយឥឡូវនឹងគួសមបន្តិចបានផ្ទះទ្រើស(ធំ)ខាងលើឈើខាងក្រោមជញ្ជាំងស៊ីម៉ងត៍គ្រាន់បើជាងកាលពីក្មេង។

កៈ ចាម៉ាក់!អញ្ចឹងបើនិយាយពីបញ្ហាជីវិត តើម៉ាក់ប្រាប់បានអត់ថាពេលដែលម៉ាក់ ពេលណាដែលម៉ាក់មានភាពលំបាកជាងគេនៅក្នុងជីវិតណា?

ខៈ ភាពលំបាកជាងគេនៅក្នុងជីវិតនឹងហ៉ា គឺនៅជំនាន់ ប៉ុល ពត នឹងហើយពិបាកជាងគេ។

ក៖ ចាំ យ៉ាងម៉េចខ្លះទៅម៉ាក់?

ខ៖ ជំនាន់នឹងវាពិបាកមែននឹងណា ទំរាំតែឆ្លងផុតពីជំនាន់អាពតមកគេ.. គេប្រើយើងនឹងណា ប្រើមិនដឹងថាយើងសសៃខ្វី មិនខ្វីអីទេ ប្រើទាំងសសៃខ្វីអោយបាយចេកបាយនឹងគ្មានគ្រាប់អង្កអោយយើងទេមានតែចេកឈូសទេណា។

ក៖ ចាម៉ាក់?

ខ៖ នឹងហើយ វាពិបាកណាស់ពីក្មេង។

ក៖ ហូបអត់គ្រប់ទេម៉ាក់ន៎?

ខ៖ មិនគ្រប់ទេ គេប្រើដូចថាគ្មានថ្ងៃថាបានដេកនឹងផ្ទះ
កូនខ្វីបានតែបីខែដេញយើងទៅស្រែ ទៅចំការហើយ ពិបាកណាស់។

ក៖ ម៉ាក់! មានកូនៗម៉ាក់ដែលគាត់ស្លាប់នឹង បកទៅវិញសំនួរចាស់ណា គាត់ស្លាប់ដោយសារអីខ្លះទៅម៉ាក់?

ខ៖ កូនច្បងឈ្មោះទៀង ឈុនឈៀង នឹងស្លាប់ដោយសាប៉ុលពត យកទៅវាយ(សំលាប់ចោល)ណា ។

ក៖ ចាំ?

ខ៖ ហើយទៅ កូនបន្ទាប់មកស្លាប់ដោយជំងឺរោគាខ្លួនឯងទេ។

ក៖ ជំងឺរោគាទេ តើគាត់ស្លាប់ជំនាន់ប៉ុល ពតដែររឺក៏ម៉េចម៉ាក់?

ខ៖ ជំនាន់ប៉ុល ពត អឺ..កាលនឹងជំនាន់ប៉ុល ពតនឹងគ្មានថ្នាំណាមើលអោយយើងដឹតដល់គាត់ស្លាប់ទៅណា គ្រុនក្ដៅគ្រុនអីទៅនឹងណា។

ក៖ ចាំម៉ាក់?

ខ៖ ហើយទៅមានមីប្អូនមួយនឹងស្លាប់ដោយខ្សែភ្លើងឆក់ទេ ហ៊ាន នឹងណា។

ក៖ ចាំ?

ខ៖ ហើយទៅអាសម្បត្តិនឹងក៏ជំងឺរោគាដែរ ស្លាប់ជំនាន់ឥឡូវទេ ទើបស្លាប់បានបីឆ្នាំនឹងទេ។

ក៖ ចាំ?

ខ៖ អាសម្បត្តិន៎វា..ស្លាប់នឹងពីរបីឆ្នាំទៅមួយទៅ ស្លាប់តែរោគាទេ អត់មានទេ ប៉ុលពតសំលាប់បានតែមួយនឹងទេ។

ក៖ ចាំម៉ាក់?

ខ៖ នឹងហើយ
 យើងធ្វើការជំនាន់នឹងសូម្បីតែអ្នកធ្វើការអីក៏ដោយ កន្លះម៉ោងក៏គេយកទៅវាយ(សំលាប់)ចោលដែរ។

ក៖ អញ្ចឹងអ្នកដែលស្លាប់នឹងរោគានឹងគាត់អត់មានធ្វើការអីធំទេ?

ខ៖ អត់ទេ។

ក៖ គាត់ធ្វើ...?

ខ៖ គាត់ធ្វើចំការស្រែយើងធម្មតាទេ អ្នកដែលស្លាប់នឹងនោះ។

ក៖ ប៉ុន្តែអ្នកដែលស្លាប់ជំនាន់ ប៉ុល ពត នឹង ពួកគាត់ធ្វើកិច្ចការងារព្រលាននោះម៉ាក់?

ខ៖ នឹងហើយ !
 អានឹងគាត់គេយកទៅវាយចោល(សំលាប់)ធ្វើការនៅអីព្រលានកប៉ាល់ហោះនឹងហ៎ា ។

ក៖ ចា?

ខ៖ គេយកទៅវាយ(សំលាប់)ចោលព្រោះយើងធ្វើការ។

ក៖ ចាំ! តើការដែលម៉ាក់មានភាពលំបាកនឹងម៉ាក់ឆ្លងកាត់បានយ៉ាងម៉េចខ្លះទៅម៉ាក់?

ខ៖ ឆ្លងកាត់ការលំបាកច្រើនដែរនឹងតាំងពីនឹងមកដល់ឥឡូវនឹង។

ក៖ ចាំ! អញ្ចឹងម៉ាក់មានបទពិសោធន៍ល្អៗនៅក្នុងជីវិតម៉ាក់ទេ?

ខ៖ មានខ្លះក៏អត់ខ្លះដែរនឹង។

ក៖ ចាំម៉ាក់?

ខ៖ ពីព្រោះវាមិនល្អមានភាគតិចដែរ។

ក៖ អាល្អមានអីខ្លះម៉ាក់អាចរៀបរាប់បានខ្លះទេម៉ាក់?

ខ៖ អាល្អ?... ។

ក៖ អាល្អណា?

ខ៖ អាល្អហ៉ោស?!។

ក៖ ចាស?

ខ៖ ហឺសៗៗ(សើច) ដូចថាយើង កាលពីជំនាន់នឹង វាសំបូរសប្បាយទៅ យើងបានដើរទៅណេះ ដើរទៅណោះ ដើរលេងគ្រប់កន្លែងណា។

ក៖ អ៎..!?

ខ៖ អឺ...។

ក៖ ចាម៉ាក់?

ខ៖ បើថា គ្រួសារនាំដើរលេងកំពង់សោមអញ្ចឹងទៅណា ទៅបូកគោអញ្ចឹងទៅ ដើរទៅលេងគ្រប់ច្រកទៅណា អាកន្លែងណាដែលយើងមិនដែលបានដើរ យើងដើរទៅលេងបានស្គាល់អស់ហើយ។ យើងបានសប្បាយខ្លះសប្បាយច្រើននិយាយអោយឃើញ។

ក៖ ចា?

ខ៖ ហឺសៗៗ(សើច)។

ក៖ អញ្ចឹងអឺ..កាលនឹងអឺ...កាលពីក្មេងម៉ាក់ធ្លាប់មានក្តីសង្ឃឹមចង់ធ្វើអ្វីពេលធំឡើងម៉ាក់?

ខ៖ អឺ..កាលនៅពីក្មេងថាធំដឹងក្ដីឡើងរៀនចប់កាលណាចង់រៀនកាត់ដេរដែរណា។

ក៖ ចា?

ខ៖ ចង់អោយខ្លួនឯងចេះកាត់ដេរ តែដល់តែពេលស្រុកកើតសង្គ្រាមដល់ពេលធំនឹងហើយអត់បានសំរេច។

ក៖ អត់បានកាត់ដេរអីទេ?

ខ៖ ហីសៗៗ(សើច)អត់បានសំរេច រៀនក៏អត់បានចប់ដែរ រៀបបានតែត្រឹមថ្នាក់ទី៧ លន់ ណុល ពិបាក។

ក៖ លន់ ណុល ?

ខ៖ ពិបាករត់លូន រត់ពួនគ្រង់សេណា ដ៏ទៅ យើងអារៀនក៏អត់បានចប់ អារៀនកាត់ដេរក៏អត់បាន រៀនកាត់ដេរពីព្រោះកាលនឹងស្រលាញ់ណាស់ជាងកាត់ដេរ។

ក៖ ចាម៉ាក់?

ខ៖  តែវាក៏អត់បានសំរេចទេ។

ក៖ ចាម៉ាក់! ហើយឥឡូវនៅតែស្រលាញ់ដដែល?

ខ៖ ឥឡូវនៅតែស្រលាញ់អញ្ចឹងបានថា កាលជំនាន់ ប៉ុល ពត នឹងគឺស្លៀកពាក់ដោយខ្លួនឯងទេ។ គ្មានជាងណាមកកាត់អោយទេកាត់ស្លៀកពាក់ខ្លួនឯងទៅ ។ ខោអាវជំនាន់អាពត នឹងដេដៃ ដេអាវដេខោស្លៀកខ្លួនឯង គ្មានជាងណាមកកាត់ខ្លួនឯងចឹងបានណាថា ដូចថា

ដុងវាប្រុងដុះខាងដេរ ស្រលាញ់ខាងដេរ តែវាអត់បានសំរេចនឹងអាពេល.. អត់បានរៀននឹងណាពីព្រោះវាអាល័យតែរត់ពួនរត់លូនទាំងអស់តែគ្នានឹង។

កៈ ចាំម៉ាក់! អាល័យតែកើតសង្គ្រាម?

ខៈ
អាល័យតែកើតសង្គ្រាម យើងបានអីទៅរៀនដេរនិង រៀនអីទៀត ដំអញ្ចឹងវាអស់ វាអត់មានអីរៀនដេរទៀតទេ។

កៈ ចាំម៉ាក់?

ខៈ នឹងហើយ។

កៈ ចុះម៉ាក់! ជាចុងក្រោយម៉ាក់មានអី ពាក្យផ្តែផ្តាំសំរាប់កូនចៅជំនាន់ក្រោយទេម៉ាក់?

ខៈ ផ្តែផ្តាំថា អោយកូនទាំងអស់ ប្រឹងធ្វើការណា។

កៈ ចា?

ខៈ អោយរៀនសូត្រអោយឆាប់ចេះដឹងទៅ ដើម្បីអនាគតយើងតទៅមុខទៀត យើងកុំខ្ជិលកុំច្រអូសអី ចេះតែប្រដៃប្រដៅកូនទាំងអស់នឹងហើយ, ជាពិសេសអាពៅចុងក្រោយ អាបងៗគេមានអនាគតគេហើយណា។

កៈ ចាំម៉ាក់?

ខៈ ប្រដៃប្រដៅអាពៅនឹងទៀតថា កូនឯងយ៉ាងណាក៏កូនឯង ប្រឹងរៀនប្រឹងសូត្រទៅណាកូន។ អោយប្រលងអោយបានចប់ អោយបានការងារធ្វើទៅ កូនឯងរកអនាគតឃើញហើយ

ព្រោះម៉ែនឹងប៉ាចាស់អស់ហើយ មិនសង្ឃឹមអីទៀតកូនហើយ សង្ឃឹមតែកូនឯងអោយតែកូនឯងរកអនាគតបានទៅមុខទៀត ម៉ែក៏ត្រេកអរដែរ ស្លាប់ទៅម៉ែបិទភ្នែកជិត។

ក៖ ចាំ?

ខ៖ គេថាមិនអីទេម៉ែ ខ្ញុំប្រឹងរៀន។

ក៖ ចាំ?

ខ៖ មិនអោយម៉ែនឹងប៉ាពិបាកទេ ចាំកុំអាលទៅណា ចាំខ្ញុំបានប្រាក់ខែមក ខ្ញុំចិញ្ចឹមម៉ែនិងប៉ាវិញ ហីសៗៗៗ(សើច) អូយចេះតែប្រដៅកូនទៅណា
កូនទាំងអស់នឹងណា។ បើថាធ្វើការក៏ធ្វើទៅកូនហើយ ធ្វើម៉េចកុំអោយគេស្អប់ អោយវាត្រង់ចំពោះការងារគេនឹងណា។ ធ្វើអីធ្វើទៅអោយតែអ្នកធំអ្នកតូចគេអាណិតអាសូ យើងកុំធ្វើអីអោយខុសឆ្គងចំពោះការងារគេណា។

ក៖ ចា?

ខ៖ នឹងហើយ។

ក៖ ម៉ាក់ ! អញ្ចឹងជាចុងក្រោយខ្ញុំអគុណម៉ាក់ដែលបានផ្តល់ការសំភាសពីជីវប្រវត្តរបស់ម៉ាក់ ហើយអញ្ចឹងអឺ..ចង់បញ្ជាក់ប្រាប់ម៉ាក់ថាអឺ..នៅពេលដែលពួកខ្ញុំធ្វើសំភាសម៉ាក់នេះហើយ ពួកខ្ញុំនឹងដាក់ការសំភាសនេះនៅក្នុងវែបសាយរបស់សាលាប៊ីវាយយូតើម៉ាក់ព្រមដែរអត់?

ខ៖ មិនប្រកែប្រកាន់អីទេ កូនដាក់ទៅណាក៏ដាក់ទៅចុះ។

ក៖ ចា?

ខ៖ ពេញចិត្តទាំងអស់។

ក៖ ហើយមានការថតរូបម៉ាក់អីជាចុងក្រោយនឹង?

ខ៖ ថតក៏ថតទៅម៉ាក់មិនស្អាតទេ តែគ្រាន់តែខ្មាស់គេ ថតវាមិនស្អាត ហាស់ៗៗៗ(សើច)។

ក៖ ចា! អញ្ចឹងអគុណច្រើនម៉ាក់សំរាប់ការសំភាសថ្ងៃនេះ?

ខ៖ ចា ហើសៗៗៗ(សើច)។